## *កំណាព្យ : កូនអកត្តញ្ញូ*
## *« បទពាក្យបួន »*

សូមជម្រាបសួរ អ្នកទាំងអស់គ្នា
ដែលបានសន្ទនា ពីកំណាព្យខ្ញុំ។
កន្លងមកនេះ ខ្ញុំបានជុំរុំ
ហើយប្រមូលផ្តុំ បង្កើតបទនេះ។
ពេលចាប់ផ្តើមសូត្រ សូមទាំងអស់គ្នា
ស្វែងរកវិជ្ជា នៅក្នុងកំណាព្យ។
ពេលចាំចេះហើយ សូមយកបន្សាប
អវិជ្ជាបាប ជៀសចេញឲ្យអស់។
ជិតចាប់ផ្តើមហើយ អ្នកដែលត្រៀមចាំ
បើមានវគ្គសាំ សូមបំភ្លេចចោល។
ចាប់ផ្តើមសូត្រទៅ កុំបោះកុំបោល
បញ្ឆោះបញ្ឆោល លើកំណាព្យនេះ។
បើមានកំហុស សូមអធ្យាស្រ័យ
សូមឲ្យតម្លៃ លើកំណាព្យខ្ញុំ។
ត្បិតយើងជាខ្មែរ ត្រូវចេះព័ទ្ធហ៊ុម
កុំចោលកុំផ្តុំ បទខ្ញុំផ្តើមហើយ។
ពេលព្រលឹមឡើង តើត្រូវធ្វើអ្វី
មាយាជកខ្ចី ដាក់ម៉ែខ្លួនឯង ។
ម៉ែក៏ចាស់ណាស់ មិនគិតរមែង
អូនបងប្រឡែង ខូចអនាគត ។
ម្តាយឈឺយ៉ាងធ្ងន់ តែនៅប្រឹងរក
ខំប្រឹងលៃលក ដើម្បីកូនស្ងួន ។
គ្មានលុយព្យាបាល រោគមួយចំនួន
ដើម្បីកូនស្ងួន ខំគ្រប់បែបយ៉ាង ។
រីឯកូនវិញ ធ្វើអ្វីរាល់ថ្ងៃ
ដើលេងម្ងៃៗ មិនគិតរៀនសូត្រ។
ឃើញអវិជ្ជា មិនចេះទាំងលោត
ដើរជាន់រហូត មិនចេះរំលង។
វិជ្ជារត់តាម បែរជារត់គេច

ចាប់វាពន្លិច
ហើយដុតវាចោល។
មិនឲ្យតម្លៃ
បែរជាបំបោល
រសាប់រសល់
រកតែផ្លូវខុស។
ដើរលេងឥតល្ហែ
ម៉ែឈឺនៅផ្ទះ
ម៉ែរើបំរះ
រកមើលចាំកូន។
កូនមកផ្ទះវិញ
ម៉ែអរលុះសូន្យ
ឪបត្រកងកូន
រីករាយស្វាគមន៍។
ម្តងហើយម្តងទៀត
កូនមិនពេញចិត្ត
ម្តាយមិនដឹងពិត
គិតថាកូនឃ្លាន។
ម៉ែផ្តើមធ្វើម្ហូប
សម្លសាច់ចៀន
ផ្លែក្រូចផ្លែមៀន
មានសព្វបែបយ៉ាង។
ហេតុស្រលាញ់កូន
ខំធ្វើគ្រប់យ៉ាង
មិនដែលស្រាកស្រាន
ឬក៏ត្អូញទេ។
ចំណែកឯកូន
រអ៊ើឥតល្ហែ
ត្អូញថាខ្ពើមម៉ែ
ម្តេចកក្រិចម្លេះ។
ពេលឮបែបនេះ
ម្តាយក៏ចម្ងល់
ឆ្ងល់អើយសែនឆ្ងល់
ម្តេចកូនស្តីថា
ម៉ែកក្រិចម្លេះ
មិនលាងហត្ថា
កូនមានវាចា
ម្តាយឈឺស្អិតទ្រូង។
ចាប់ម៉ែទៅលាង
ដុះខាត់ជម្រះ
ស្បែកម៉ែរយះ
ដោយសារដៃកូន។
ម៉ែគិតក្នុងចិត្ត
ដឹងឡើងសាបសូន្យ
ម៉ែទើបដឹងកូន
មានចិត្តអប្រិយ។
គាត់យំម្តងទៀត
ពោលទៅកូនថា
ឱ!នែ៎បុផ្ផា
ម៉ែពិតឈឺណាស់។
សូមកូនឈប់ទៅ
ម៉ែនេះក៏ចាស់
វាគ្មានថ្នាំសាស្ត្រ
ឲ្យម៉ែស្អាតទេ។
កូននៅមិនឈប់
រឹតតែប្រឹងថែម
ពោលយ៉ាងផ្អែមល្ហែម
ទៅកាន់ម៉ែថា។
បើស្រលាញ់ខ្ញុំ
ត្រូវធ្វើតាមណា
គឺមានតម្រា
ម៉ែឈប់កក្រិច។
ទុកម៉ែត្រាំចោល
ហើយរត់ទៅបាត់
អណ្តែតរសាត់
ទៅរកផ្លូវខុស។

ម៉ែត្រាំទឹកចោល សាច់ម៉ែឡើងសុះ
គំនិតគាត់ផុស ថាគាត់ចង់ស្លាប់។
ស្លាប់ទៅប្រសើរ ជាងជារស់នៅ
កូនដើរខុសផ្លូវ ម៉ែត្រូវទៅហើយ។
ម៉ែសម្រេចចិត្ត និងបានចម្លើយ
កូននឹងបានស្បើយ ពេលម៉ែទៅបាត់។
ដើរលេងដល់យប់ ព្រលប់ចូលផ្ទះ
ឥទ្ធិពលម៉ែជះ មកលើខ្លួនកូន។
កូនរត់ទៅមើល ចិត្តរលាយសូន្យ
ម៉ែទៅចោលកូន មិនប្រាប់មួយម៉ាត់។
ពេលម៉ែទៅបាត់ ទើបស្តាយស្រណោះ
ខ្លួនកូនក្សិណខ្សោះ ព្រោះគ្មានញាតិទេ។
ម៉ែជាញាតិមួយ មកពីបុព្វេ
មិនមានម៉ែទេ កូនអស់ញាតិហើយ។
កូនគិតក្នុងចិត្ត ត្បិតដឹងខ្លួនខុស
ខំកែកំហុស តែឥតប្រយោជន៍។
កូនគិតដុះខាត់ រឿងប៉ិនស្រមោច
មិនគួរម៉ែខ្លោច និងរឿងប៉ុណ្ណឹង។
ព្រឹកព្រលឹមហើយ លក់ផ្ទះចោលបាត់
ដើម្បីបំបាត់ ទុក្ខសោកទាំងឡាយ។
យំហើយយំទៀត នឹកស្រណោះស្តាយ
នឹកដល់អ្នកម្តាយ ដែលចាស់ជរា។
ស្លាប់ទាំងវេទនា គ្មានអ្នកណាដឹង
គ្មានអ្នកខំប្រឹង ជួយយកអាសារ។
ពេលម៉ែទៅបាត់ ទើបកូនប្រាថ្នា
ចង់ចរចង់ចារ និងម៉ែម្តងទៀត។
ដើរទៅដើរមក គ្មានមានអ្វីធ្វើ
លែងមានទង្វើ ថានឹងដើរលេង។
ប្រាក់កាក់ក៏គ្មាន មានតែសម្លេង
សម្រិតសម្រេង សុំទានគេហើយ។
ពេលម៉ែស្លាប់ទៅ មិត្តភក្តិក៏គ្មាន
គេចេះគេមាន គេទៅឆ្ងាយបាត់។
យើងធ្លាក់ខ្លួនក្រ ចាប់ផ្តើមរសាត់

គេគេចយើងបាត់ ព្រោះយើងគ្មានទ្រព្យ។
ពេលយប់ៗឡើង ប្រញាប់ប្រញាល
ឲ្យដល់ទាន់កាល គេបោះបាយបិណ្ឌ។
សូម្បីប្រេតខ្មែរ ប្រេតយួនប្រេតចិន
គឺគេចង់មិន ចែកបាយឲ្យទេ។
នេះជាជីវិត មនុស្សម្នាក់ៗ
ខ្ញុំមិនចង់លាក់ ចង់បាំងអ្វីឡើយ។
ម៉ែឪនៅរស់ ទារមិនចេះស្បើយ
មិនដែលគិតឡើយ ថាគាត់ទៅចោល។
ដល់ពេលទៅបាត់ ទើបចាប់ផ្ដើមនឹក
ចាប់ផ្ដើមរលឹក ចង់បានមកវិញ។
ពេលគាត់នៅរស់ ម្ដេចតែងបណ្ដេញ
ថាគាត់គឺជ្រេញ មិនចង់ឃើញមុខ។
យើងទាំងអស់គ្នា សូមគិតជាថ្មី
សូមស្វែងសេចក្ដី អ្វីទៅឪពុកម្ដាយ ?
ខំប្រឹងធ្វើបុណ្យ ខំប្រឹងចំណាយ
ពេលដែលសប្បាយ ជាមួយពួកគាត់។
ពេលធ្វើបែបហ្នឹង គាត់និងសប្បាយ
គាត់មិនខ្វល់ខ្វាយ គាត់មិនឈឺចាប់។
ព្រោះកូនៗគាត់ សុទ្ធតែចំណាប់
យើងមិនឈឺចាប់ គ្រួសាររីករាយ។